# ព្រះរាជក្រម

នស/រកម/១១១៦/០១៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី៧ ស្តីពីប្រព័ន្ធឆ្លងកាត់គយ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីកិច្ចសម្រួលការដឹកជញ្ជូនឆ្លងកាត់ទំនិញ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៦ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើពិធីសារទី ៧ ស្តីពីប្រព័ន្ធឆ្លងកាត់គយ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីកិច្ចសម្រួលការដឹកជញ្ជូនឆ្លងកាត់ទំនិញ

**មាត្រា ១.-**

អនុម័តយល់ព្រមលើពិធីសារទី ៧ ស្តីពីប្រព័ន្ធឆ្លងកាត់គយ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីកិច្ចសម្រួលការដឹកជញ្ជូនឆ្លងកាត់ទំនិញ ដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខានៅរាជធានីបាងកក នៃព្រះរាជាណាចក្រថៃ នាថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៥ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារនេះ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ២០១៦

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកម.១៦១១.១០៧៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ហត្ថលេខា**
**អូន ព័ន្ធមុនីរ័ត្ន**

**លេខ:១០៦២ស.ណ**
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ស៊យ សុខា**

# ពិធីសារទី៧
# ស្តីពី
# ប្រព័ន្ធឆ្លងកាត់គយ

រដ្ឋាភិបាលនៃព្រុយណេដារូសារឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ម៉ាឡេស៊ី សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រទេសសមាជិកនៃប្រជាជាតិអាស៊ីអាគ្នេយ៍ (ដែលហៅថា "បណ្តាប្រទេសសមាជិក" ឬតែមួយហៅថា "ប្រទេសសមាជិក")

**ដោយរំលឹកឡើងវិញ** កិច្ចព្រមព្រៀងក្របខណ្ឌអាស៊ានស្តីពីកិច្ចសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ទំនិញ ដែលបានចុះហត្ថលេខានៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៨ នៅរដ្ឋធានីហាណូយ ប្រទេសវៀតណាម (ហៅថា "កិច្ចព្រមព្រៀង")

**ដោយទទួលស្គាល់** មាត្រា១៨និងមាត្រា២៥ ខាងក្រោម ផ្តល់ការសន្មតនៃការអនុវត្តពិធីសារនានា ដែលត្រូវជាផ្នែករបស់កិច្ចព្រមព្រៀងនេះ

**ដោយរំលឹកឡើងវិញ** ប្រព័ន្ធឆ្លងកាត់គយអាស៊ាន គឺជាកិច្ចដំណើរការការងារឆ្ពោះទៅការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន ដូចដែលមានចែងក្នុងឯកសារគោលរបស់សហគមន៍សេដ្ឋកិច្ចអាស៊ាន

**ដោយមានគោលបំណង** លើកទឹកចិត្តនិងសម្រួលប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់និងដឹកជញ្ជូនអន្តររដ្ឋនៅក្នុងចំណោមបណ្តាប្រទេសសមាជិក

**ដោយឯកភាពបញ្ជាក់ថា** ការសន្និដ្ឋានរបស់ពិធីសារនេះនឹងផ្តល់ការរៀបចំប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផលដល់ពាណិជ្ជកម្មដឹកជញ្ជូនឆ្លងកាត់ក្នុងបណ្តាប្រទេសសមាជិក

**បានយល់ព្រម** ដូចខាងក្រោម៖

## មាត្រា១.- និយមន័យ

គោលបំណងនៃពិធីសារនេះគឺ៖

ក- "ប្រព័ន្ធឆ្លងកាត់គយអាស៊ាន" ឬ "ACTS" គឺជាប្រព័ន្ធគយនៃការដឹកជញ្ជូនឆ្លងកាត់ក្រោមការត្រួតពិនិត្យរបស់គយ ដើម្បីសម្រួលចរាចរទំនិញឆ្លងកាត់ក្នុងដែនមួយឬច្រើននៃភាគីហត្ថលេខីដែលមានចែងក្នុងពិធីសារនេះ។ នៅពេលដែលមានដំណើរឆ្លងកាត់ដែនប្រទេសមួយឬច្រើន គឺគ្រាន់តែជាចំណែកមួយនៃការចាប់ផ្តើមនិងការបញ្ចប់នៃការធ្វើដំណើរនៅក្រៅព្រំដែនមួយឬច្រើននៃភាគីហត្ថលេខី ដោយឆ្លងកាត់ដែននៃភាគីហត្ថលេខីទាំងនេះសម្រាប់ចរាចរទំនិញឆ្លងកាត់

ខ- "នីតិវិធីប្រព័ន្ធឆ្លងកាត់គយអាស៊ាន" គឺជាវិធាននិងនីតិវិធីគ្រប់គ្រងលើប្រព័ន្ធឆ្លងកាត់គយអាស៊ាន ដូចមានចែងក្នុងពិធីសារនេះនិងឧបសម្ព័ន្ធបច្ចេកទេសភ្ជាប់ជាមួយ

គ- "អាជ្ញាធរមានសមត្ថកិច្ច" គឺជាសមត្ថកិច្ចគយឬសមត្ថកិច្ចផ្សេងទៀតដែលទទួលខុសត្រូវអនុវត្តបញ្ញត្តិនៃពិធីសារនេះ

ឃ- "គយ" គឺជាអាជ្ញាធរគយនៃភាគីហត្ថលេខី

ង- "បំណុលគយ" គឺជាពន្ធគយ អាករ និងកម្រៃផ្សេងទៀតដែលអាចបង់នៅពេលទំនិញដាក់ឲ្យស្ថិតក្រោមការអនុវត្តនីតិវិធីប្រព័ន្ធឆ្លងកាត់គយអាស៊ាននេះ

ច- "ការិយាល័យគយដើមទី" គឺជាការិយាល័យគយដែលប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់ចាប់ផ្តើម

ឆ- "ការិយាល័យគយគម្យដ្ឋាន" គឺជាការិយាល័យគយដែលប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់បានបញ្ចប់

ជ- "ការិយាល័យគយឆ្លងកាត់" គឺជាការិយាល័យគយណាមួយនៅចំណុចចាកចេញឬចូលទៅក្នុងដែននៃភាគីហត្ថលេខី ក្រោមបរិបទប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់

ឈ- "ប្រតិវេទន៍គយឆ្លងកាត់" គឺជាសេចក្តីប្រកាសដែលត្រូវបំពេញដោយប្រតិវេទករដើមសម្រាប់ដាក់ជូនការិយាល័យគយដើមទី ដើម្បីដាក់ទំនិញឲ្យស្ថិតក្រោមនីតិវិធីប្រព័ន្ធឆ្លងកាត់គយអាស៊ាន

៣- "បច្ចេកទេសដំណើរការទិន្នន័យ" គឺជាសេចក្តីណែនាំស្តីពីព័ត៌មានដែលត្រូវបំពេញបែបបទពាក់ព័ន្ធ ក្នុងប្រព័ន្ធដំណើរការទិន្នន័យរបស់អាជ្ញាធរមានសមត្ថកិច្ចឬការផ្លាស់ប្តូរសារស្តង់ដាអេឡិចត្រូនិក ជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ច

៤- "អ្នកធានា" គឺជារូបវន្តបុគ្គលឬនីតិបុគ្គលទី៣ ដែលទទួលរ៉ាប់រងក្នុងការទូទាត់រួមគ្នា ឬដោយភាគខ្លះ ជាលាយលក្ខណ៍អក្សរ ជាមួយប្រតិវេទករនូវរាល់បំណុលគយ ហួតគ្រប់ចំនួនប្រាក់ដែលដាក់ធានា

៥- "ការិយាល័យនិមុត្តិធានា" គឺជាការិយាល័យមួយឬច្រើនដែលកំណត់ដោយភាគីហត្ថលេខីដើម្បីគ្រប់គ្រងនិមុត្តិធានានៅក្នុងប្រទេសនោះ សម្រាប់ផ្តល់ការអនុញ្ញាតឲ្យអ្នកធានានិងសម្រាប់គ្រប់គ្រងនិមុត្តិធានាលើកិច្ចប្រតិបត្តិការឆ្លងកាត់

៦- "ប្រតិវេទករដើម" គឺជាបុគ្គលដែលដាក់ទំនិញឲ្យស្ថិតនៅក្រោមនីតិវិធីប្រព័ន្ធឆ្លងកាត់គយអាស៊ាន បើទោះជាធ្វើដោយតំណាងដែលទទួលបានការអនុញ្ញាតក៏ដោយ

៧- "ប្រតិបត្តិការឆ្លងកាត់" គឺជាការដឹកជញ្ជូនទំនិញពីការិយាល័យគយដើមទី ទៅកាន់ការិយាល័យគយគម្យដ្ឋាន ក្រោមការអនុវត្តនីតិវិធីប្រព័ន្ធឆ្លងកាត់គយអាស៊ាន។

## មាត្រា២.- ទំហំនៃការអនុវត្ត

អនុលោមតាមមាត្រា១៨.១នៃកិច្ចព្រមព្រៀង បណ្តាប្រទេសសមាជិកព្រមព្រៀងបង្កើតប្រព័ន្ធឆ្លងកាត់គយអាស៊ាននិងអនុវត្តបញ្ញត្តិនៃពិធីសារនេះ សម្រាប់ការដឹកជញ្ជូនឆ្លងកាត់ទំនិញក្នុងដែនរបស់បណ្តាប្រទេសសមាជិក។

## មាត្រា៣.- បញ្ញត្តិទូទៅ

១- ដោយគ្មានការប៉ះពាល់ដល់កថាខណ្ឌ២និងកថាខណ្ឌ៣នៃមាត្រានេះ ប្រទេសសមាជិកនីមួយៗត្រូវអនុញ្ញាតឲ្យដឹកជញ្ជូនទំនិញឆ្លងកាត់ដែនរបស់ខ្លួន ក្រោមនីតិវិធីប្រព័ន្ធឆ្លងកាត់គយអាស៊ាន។

២- ប្រទេសសមាជិកអាចហាមឃាត់និង/ឬដាក់កម្រិតកំណត់ទំនិញមួយចំនួនពីការប្រើប្រាស់នីតិវិធីប្រព័ន្ធឆ្លងកាត់គយអាស៊ាន ក្រោមលក្ខខណ្ឌសីលធម៌សាធារណៈ គោលនយោបាយសាធារណៈ ឬសន្តិសុខសាធារណៈ ការពារសុខុមាលភាពនិងជីវិតមនុស្ស សត្វ ឬរុក្ខជាតិ ការការពារ

បេតិកភណ្ឌជាតិដែលមានតម្លៃខាងសិល្បៈប្រវត្តិសាស្ត្រ ឬបុរាណវត្ថុវិទ្យា ឬការការពារទ្រព្យសម្បត្តិពាណិជ្ជកម្មឬឧស្សាហកម្ម។

៣- បន្ទាប់ពីបានចុះហត្ថលេខាលើពិធីសារនេះ បញ្ជីទំនិញហាមឃាត់និង/ឬទំនិញជាប់កម្រិតកំណត់របស់ប្រទេសសមាជិកនីមួយៗ ត្រូវចែងក្នុងឧបសម្ព័ន្ធភ្ជាប់នឹងពិធីសារនេះ។ ប្រទេសសមាជិកនីមួយៗអាចធ្វើវិសោធនកម្មបញ្ជីទំនិញហាមឃាត់និង/ឬទំនិញជាប់កម្រិតកំណត់ ដោយត្រូវជូនដំណឹងឲ្យបានឆាប់មកអគ្គលេខាធិការអាស៊ាន ចំពោះការធ្វើវិសោធនកម្មនេះ។ អគ្គលេខាធិការអាស៊ានត្រូវជូនដំណឹងឲ្យបានឆាប់ចំពោះការធ្វើបច្ចុប្បន្នកម្មនៃឧបសម្ព័ន្ធនេះទៅឲ្យបណ្តាភាគីហត្ថលេខី។

៤- ទំនិញដែលស្ថិតនៅក្រោមនីតិវិធីប្រព័ន្ធឆ្លងកាត់គយអាស៊ាន នឹងមិនត្រូវជាកម្មវត្ថុនៃការបង់ពន្ធនិងអាករ លើកលែងតែកម្រៃដឹកជញ្ជូន ចំណាយរដ្ឋបាលសម្រាប់ការឆ្លងកាត់ ឬកម្រៃសេវាកម្មដែលត្រូវបង់ ក្នុងករណីដែលបញ្ញត្តិនៃនីតិវិធីប្រព័ន្ធឆ្លងកាត់គយអាស៊ានត្រូវអនុវត្តនិងនិមុត្តិធានាត្រូវបង់ ដែលមានចែងក្នុងមាត្រា៥ នៃពិធីសារនេះ។ ទោះបីយ៉ាងណា បញ្ញត្តិនេះមិនហាមឃាត់៖

- ក- ការប្រមូលពន្ធនិងអាករនៅក្នុងប្រទេសនាំចេញ ខណៈដែលពន្ធនិងអាករទាំងនេះត្រូវបង់ទោះបីជាទំនិញត្រូវនាំចេញក្រោមការឆ្លងកាត់ឬក្រោមនីតិវិធីនាំចេញជាតិ ឬ
- ខ- ការប្រមូលពន្ធនិងអាករ នៅក្នុងប្រទេសគម្យដ្ឋាន ខណៈដែលប្រតិបត្តិការឆ្លងកាត់ត្រូវបញ្ចប់និងទំនិញត្រូវបញ្ចេញពីគយសម្រាប់ប្រើប្រាស់។

៥- លក្ខខណ្ឌដែលត្រូវបំពេញនិងទម្រង់បែបបទគយដែលត្រូវអនុវត្តសម្រាប់ប្រតិបត្តិការឆ្លងកាត់ ត្រូវមានចែងក្នុងបទប្បញ្ញត្តិជាតិនិង/ឬសេចក្តីជូនដំណឹងរដ្ឋបាល ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

៦- ជាវិធានទូទៅ ទំនិញដែលដាក់ក្រោមនីតិវិធីប្រព័ន្ធឆ្លងកាត់គយអាស៊ានត្រូវបានលើកលែងពី៖

- ក- ការត្រួតពិនិត្យជារូបវន្តដោយគយលើតម្រាយផ្លូវ ក្រៅពីការត្រួតពិនិត្យត្រានិងការប្រើប្រាស់បច្ចេកវិទ្យាត្រួតពិនិត្យដោយគ្មានការរំខាន។
- ខ- ការអមឃ្លាំមើលទំនិញរបស់គយ និង
- គ- ការតម្រូវឲ្យតម្កល់និមុត្តិធានាឬមូលបត្របំណុលមានចែងក្នុងពិធីសារនេះនិងឧបសម្ព័ន្ធបច្ចេកទេសភ្ជាប់ជាមួយ។

៧- ប្រទេសសមាជិកត្រូវលើកកម្ពស់ការប្រើប្រាស់ ប្រព័ន្ធព័ត៌មានវិទ្យា ទូរគមនាគមន៍ និង បច្ចេកទេសគ្រប់គ្រងហានិភ័យដែលពាក់ព័ន្ធនឹងនីតិវិធីនៃការគ្រប់គ្រងប្រព័ន្ធឆ្លងកាត់គយអាស៊ាន ដើម្បីធានាឲ្យបាននូវការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពសម្រាប់គយនិងធុរជន។

**មាត្រា៤.- ប្រតិវេទន៍គយឆ្លងកាត់**

១- ប្រតិវេទន៍គយឆ្លងកាត់ត្រូវបំពេញដោយប្រតិវេទករដើមឬអ្នកតំណាងដែលទទួលសិទ្ធិ ដើម្បីប្រកាសអំពីទំនិញឆ្លងកាត់ ក្រោមនីតិវិធីប្រព័ន្ធឆ្លងកាត់គយអាស៊ាន។

២- ប្រតិវេទន៍គយឆ្លងកាត់និងឯកសារពាក់ព័ន្ធសម្រាប់គោលបំណងនៃការអនុវត្តនីតិវិធី ប្រព័ន្ធឆ្លងកាត់គយអាស៊ាន ត្រូវធ្វើឡើងស្របតាមឧបសម្ព័ន្ធបច្ចេកទេសនៃពិធីសារនេះ។

**មាត្រា៥.- និមុត្តិធានាសម្រាប់បំណុលគយ**

១- ដើម្បីធានាការទូទាត់បំណុលគយដែលអាចកើតឡើង នៅពេលទំនិញដាក់ក្រោមនីតិវិធី ប្រព័ន្ធឆ្លងកាត់គយអាស៊ាននិងមានការលើកលែងតែករណីផ្សេងពីនេះ ប្រតិបត្តិការឆ្លងកាត់ត្រូវ គ្រប់ដណ្តប់ដោយនិមុត្តិធានាដែលមានសុពលភាពសម្រាប់បណ្តាប្រទេសសមាជិកចូលរួមក្នុង ប្រតិបត្តិការនេះ។

២- និមុត្តិធានាត្រូវតម្កល់ដោយប្រតិវេទករដើមនិងទឹកប្រាក់អតិបរមាមិនត្រូវលើសពី បំណុលគយដែលត្រូវទូទាត់។

៣- អ្នកធានាត្រូវតែងតាំងនិងយល់ព្រមដោយការិយាល័យនិមុត្តិធានា ក្នុងប្រទេសសមាជិក ដែលនិមុត្តិធានាត្រូវតម្កល់។ អ្នកធានាត្រូវផ្តល់អាសយដ្ឋានច្បាស់លាស់សម្រាប់ទំនាក់ទំនងផ្នែក សេវាកម្ម ក្នុងដែនរបស់ប្រទេសសមាជិកនីមួយៗដែលចូលរួមក្នុងប្រតិបត្តិការឆ្លងកាត់គយ។ ក្នុងករណី ដែលអ្នកធានាពុំមានអាសយដ្ឋានសម្រាប់ទំនាក់ទំនងសេវាកម្ម អ្នកធានាត្រូវតែងតាំងភ្នាក់ងារក្នុង ប្រទេសសមាជិកនីមួយៗដែលចូលរួមក្នុងប្រតិបត្តិការឆ្លងកាត់គយ។

**មាត្រា៦.- ឧប្បត្តិហេតុនៅតាមតម្រាយផ្លូវ**

ក្នុងករណីដែលមានការបាត់បង់ឬការខូចខាតនូវទំនិញ ការដាច់រហែកសៀលគយ ឬ ឧប្បត្តិហេតុផ្សេងទៀត ឬគ្រោះថ្នាក់ដែលអាចជះឥទ្ធិពលដល់លទ្ធភាពស្របច្បាប់នៃការអនុវត្តនីតិវិធី

ប្រព័ន្ធឆ្លងកាត់គយអាស៊ាន ប្រតិវេទករដើម ប្រតិបត្តិករដឹកជញ្ជូន ឬបុគ្គលផ្សេងទៀតដែលទទួលខុសត្រូវគ្រប់គ្រងទំនិញ ត្រូវរាយការណ៍ជាបន្ទាន់ពីឧប្បត្តិហេតុនេះទៅឲ្យអាជ្ញាធរមានសមត្ថកិច្ច នៃប្រទេសសមាជិក ដែលមធ្យោបាយដឹកជញ្ជូនស្ថិតក្នុងដែនរបស់ប្រទេសសមាជិកនេះ និងត្រូវអនុវត្តបទប្បញ្ញត្តិនិងនីតិវិធីសម្រាប់ឧប្បត្តិហេតុ ដោយអនុលោមតាមឧបសម្ព័ន្ធបច្ចេកទេសនៃពិធីសារនេះ។

**មាត្រា៧.- បទល្មើសគយ**

១- ប្រទេសសមាជិកនីមួយៗ ត្រូវមានសិទ្ធិដកហូតជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍នូវការប្រើប្រាស់នីតិវិធីប្រព័ន្ធឆ្លងកាត់គយអាស៊ាន ចំពោះបុគ្គលណាដែលប្រព្រឹត្តបទល្មើសច្បាប់គយ ឬច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតអនុលោមតាមការដឹកជញ្ជូនទំនិញជាអន្តរជាតិ ដែលសិទ្ធិដកហូតនេះ គឺស្ថិតក្រោមការវិនិច្ឆ័យរបស់អាជ្ញាធរមានសមត្ថកិច្ច។

២- រាល់បទល្មើសគយដែលរកឃើញពាក់ព័ន្ធនឹងប្រតិបត្តិការឆ្លងកាត់ ត្រូវផ្តន្ទាទោសអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាតិរបស់ប្រទេសសមាជិកនីមួយៗ។

**មាត្រា៨.- នីតិវិធីសាមញ្ញកម្ម**

១- អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសសមាជិក ដែលក្នុងដែនអនុវត្តសិទ្ធិអំណាចរបស់ខ្លួនអាចអនុញ្ញាតឲ្យធុរជនមួយចំនួនប្រើប្រាស់នីតិវិធីសាមញ្ញសម្រាប់ប្រតិបត្តិការឆ្លងកាត់គយ។

២- ការទទួលខុសត្រូវរបស់ធុរជនដែលទទួលបានការអនុញ្ញាតក្រោមនីតិវិធីសាមញ្ញកម្មនេះមានចែងក្នុងឧបសម្ព័ន្ធបច្ចេកទេសនៃពិធីសារនេះ។

**មាត្រា៩.- ការជួយគ្នាផ្នែករដ្ឋបាលនិងការទាមទារ**

អាជ្ញាធរមានសមត្ថកិច្ច នៃបណ្តាប្រទេសសមាជិកត្រូវជួយគ្នាទៅវិញទៅមកដោយអនុលោមទៅតាមច្បាប់និងបទប្បញ្ញត្តិជាតិរបស់ខ្លួនក្នុងការសាកសួរនិងស៊ើបអង្កេតនិង/ឬការទាមទារណាមួយ ដែលកើតឡើងពីប្រតិបត្តិការឆ្លងកាត់គយ។

**មាត្រា១០.- ស្ថាប័នចាត់ចែង**

១- កិច្ចប្រជុំអគ្គនាយកគយអាស៊ាន ត្រូវទទួលខុសត្រូវនូវការគ្រប់គ្រង ត្រួតពិនិត្យសារឡើងវិញ សម្របសម្រួល និងត្រួតពិនិត្យគ្រប់ទិដ្ឋភាពនានាពាក់ព័ន្ធនឹងការអនុវត្តពិធីសារនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។ កិច្ចប្រជុំអគ្គនាយកគយអាស៊ានអាចចាត់តាំងក្រុមការងារឬគណៈកម្មាធិការ

មួយចំនួនដែលពាក់ព័ន្ធ ដើម្បីជួយបំពេញការទទួលខុសត្រូវរបស់ខ្លួនក្នុងការអនុវត្តពិធីសារនេះ។

២- លេខាធិការដ្ឋានអាស៊ានត្រូវផ្តល់ការឧបត្ថម្ភចាំបាច់ផ្នែករដ្ឋបាលនិងជាជំនួយការសម្រាប់កិច្ចប្រជុំអគ្គនាយកគយអាស៊ាន ដើម្បីអនុវត្តតួនាទី ភារកិច្ច និងការទទួលខុសត្រូវដែលមានចែងក្នុងពិធីសារនេះ។

៣- រាល់ការធ្វើវិសោធនកម្មឧបសម្ព័ន្ធបច្ចេកទេសនៃពិធីសារនេះ ត្រូវសម្រេចអនុម័តដោយកិច្ចប្រជុំអគ្គនាយកគយអាស៊ាន។ វិសោធនកម្មទាំងនេះត្រូវភ្ជាប់ជាឧបសម្ព័ន្ធរដ្ឋបាលនៃពិធីសារនេះនិងជាផ្នែកមួយនៃនៃពិធីសារនេះផងដែរ។

## មាត្រា១១.- បញ្ញត្តិផ្សេងទៀត

១- ប្រទេសសមាជិកនីមួយៗ ត្រូវចាត់វិធានការសមស្របមួយដើម្បីធានាថាបញ្ញត្តិនៃពិធីសារនេះ ត្រូវបានអនុវត្តប្រកបដោយសុខដុមនីយកម្មនិងប្រសិទ្ធផល ដោយត្រូវពិចារណាលើភាពចាំបាច់ក្នុងការកាត់បន្ថយតាមលទ្ធភាព ដែលអាចធ្វើបាននូវបែបបទនានាដែលមិនចាំបាច់តម្រូវឲ្យភាគីចូលរួមប្រើប្រាស់នីតិវិធីប្រព័ន្ធឆ្លងកាត់គយអាស៊ានអនុវត្ត ដោយឈរលើស្មារតីនៃប្រយោជន៍រួម និងការយោគយល់គ្នាទៅវិញទៅមកក្នុងការដោះស្រាយនូវការលំបាកនានាដែលនឹងអាចជួបប្រទះក្នុងការអនុវត្តនូវពិធីសារនេះ ។

២- តាមលទ្ធភាពនិងស្របតាមច្បាប់ជាតិរបស់ខ្លួន បណ្តាប្រទេសសមាជិកត្រូវផ្តល់ឲ្យគ្នាទៅវិញទៅមកនូវរាល់ព័ត៌មាននិងជូនដំណឹងឲ្យគ្នាទៅវិញទៅមកអំពីការដាក់ចេញនូវវិធានការនានាដែលអាចប៉ះពាល់ដល់ការប្រតិបត្តិការនៃពិធីសារនេះ។

## មាត្រា១២.- អវសានប្បញ្ញត្តិ

១- ពិធីសារនេះត្រូវតម្កល់ទុកនៅលេខាធិការដ្ឋានអាស៊ាន ដែលជាអ្នកត្រូវបញ្ជូនជាបន្ទាន់នូវច្បាប់ចម្លងដែលមានការបញ្ជាក់ថា បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម មួយច្បាប់ជូនទៅគ្រប់ប្រទេសសមាជិកនីមួយៗ។

២- ពិធីសារនេះ រួមទាំងឧបសម្ព័ន្ធនិងឧបសម្ព័ន្ធបច្ចេកទេស គឺជាផ្នែកនៃកិច្ចព្រមព្រៀង។ ក្នុងករណីដែលគ្មានសង្គតិភាព ឬមានអត្ថន័យមិនស្របគ្នាណាមួយក្នុងពិធីសារនេះ នោះកិច្ចព្រមព្រៀងត្រូវយកជាគោល។

៣- ពិធីសារនេះត្រូវតែជាកម្មវត្ថុនៃការផ្តល់សច្ចាប័ន ឬការទទួលយកដោយបណ្តាប្រទេសសមាជិក។ លិខិតុបករណ៍នៃការធ្វើសច្ចាប័ន ឬការទទួលយកត្រូវតម្កល់ទុកជូនអគ្គលេខាធិការអាស៊ាន ដែលជាអ្នកត្រូវជូនដំណឹងទៅប្រទេសសមាជិកនីមួយៗអំពីការទទួលតម្កល់ទុកនេះ។

៤- ពិធីសារនេះត្រូវចូលជាធរមាន បន្ទាប់ពីគ្រប់បណ្តាប្រទេសសមាជិកទាំងអស់បានតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការទទួលយកដោយអគ្គលេខាធិការអាស៊ាន។

៥- ពិធីសារនេះគ្មានចែងអំពីការបម្រុងទុកណាមួយឡើយ ទាំងនៅពេលចុះហត្ថលេខា ឬការផ្តល់សច្ចាប័ន ឬការទទួលយក។

៦- លើកលែងតែការធ្វើវិសោធនកម្មចំពោះឧបសម្ព័ន្ធនិងឧបសម្ព័ន្ធបច្ចេកទេសដែលមានចែងក្នុងកថាខណ្ឌ៣នៃមាត្រា៣និងកថាខណ្ឌ៣នៃមាត្រា១០ នៃពិធីសារនេះ ការធ្វើវិសោធនកម្មបញ្ញត្តិណាមួយនៃពិធីសារនេះ ត្រូវតែមានការព្រមព្រៀងពីគ្រប់បណ្តាប្រទេសសមាជិកទាំងអស់។

ដើម្បីជាសក្ខីភាព ហត្ថលេខីខាងក្រោមដែលបានទទួលសិទ្ធិប្រទានពីរដ្ឋាភិបាលរៀងៗខ្លួនបានចុះហត្ថលេខាលើពិធីសារទី៧ ស្តីពីប្រព័ន្ធឆ្លងកាត់គយ ដើម្បីអនុវត្តកិច្ចព្រមព្រៀងក្របខណ្ឌអាស៊ានស្តីពីកិច្ចសម្រួលទំនិញឆ្លងកាត់។

ធ្វើនៅក្រុងបាងកក ព្រះរាជាណាចក្រថៃ នាថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៥ ច្បាប់ដើមតែមួយ ជាភាសាអង់គ្លេស។

សម្រាប់រដ្ឋាភិបាលនៃព្រុយណេដារូសាឡឹម

**ប៉េហ៊ីន ដាតូ អេប៊ីឌី រ៉ាម៉ាន់ អ៊ីប្រ៉ាហ៊ីម**
រដ្ឋមន្ត្រីហិរញ្ញវត្ថុទី II នៃខុទ្ទកាល័យនាយករដ្ឋមន្ត្រី

សម្រាប់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

**គាត ឈន់**

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រាប់រដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូនេស៊ី

**អាគូស ឌី ដាប់ម៉ើលយូ ម៉ាតុវ៉ាដូដូ**

រដ្ឋមន្ត្រីហិរញ្ញវត្ថុ

សម្រាប់រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ

**សានទីភាប ភុំវីហាន់**

អនុរដ្ឋមន្ត្រីហិរញ្ញវត្ថុ

សម្រាប់រដ្ឋាភិបាលនៃម៉ាឡេស៊ី

**ដាតូ សេរី អាមីដ ហ៊ូនី មហាមេត ហាណាដាស**

រដ្ឋមន្ត្រីហិរញ្ញវត្ថុទី II

សម្រាប់រដ្ឋាភិបាលនៃសហភាពមីយ៉ាន់ម៉ា

**យូ វីន សេង**
រដ្ឋមន្ត្រីហិរញ្ញវត្ថុនិងចំណូល

សម្រាប់រដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីន

**សេរ៉ា វី ប៉ូរីសីម៉ា**
រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ

សម្រាប់រដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី

**ថាម៉ាន់ សាន់ម៉ូកាណាំ**
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីហិរញ្ញវត្ថុ

សម្រាប់រដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ

**សុំម៉ៅ ផាស៊ី**
រដ្ឋមន្ត្រីហិរញ្ញវត្ថុ

សម្រាប់រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម

**ទ្រុង ជីតុង**
អនុរដ្ឋមន្ត្រីហិរញ្ញវត្ថុ

# ឧបសម្ព័ន្ធបច្ចេកទេស
# វិធាននិងនីតិវិធីឆ្លងកាត់គយអាស៊ាន
# ផ្នែកទី១
# បទប្បញ្ញត្តិនិងនីតិវិធីទូទៅ

## មាត្រា១.- វិសាលភាព

ដូចមានចែងក្នុងពិធីសារទី៧ ស្តីពី " ប្រព័ន្ធឆ្លងកាត់គយ " ឧបសម្ព័ន្ធនេះកំណត់ពីវិធាន និងនីតិវិធីក្នុងការគ្រប់គ្រងប្រព័ន្ធឆ្លងកាត់គយអាស៊ាន ។

## មាត្រា២.- ភារកិច្ចរបស់បុគ្គលជានាឆ្លងកាត់គយ

១- ក្នុងការដាក់ទំនិញក្រោមនីតិវិធីប្រព័ន្ធឆ្លងកាត់គយអាស៊ាន បុគ្គលជានាឆ្លងកាត់គយត្រូវទទួលខុសត្រូវទូទាត់រាល់បំណុលពន្ធនិងអាករគយដែលអាចបង្កឡើងដោយសារភាពមិនប្រក្រតីកើតឡើងមុនពេលប្រតិបត្តិការឆ្លងកាត់ត្រូវបានបញ្ចប់។ ការទទួលខុសត្រូវនេះ អនុវត្តដោយស្មើភាពចំពោះទំនិញដាក់ក្រោមនីតិវិធីប្រព័ន្ធឆ្លងកាត់គយអាស៊ាន ដោយតំណាងដែលទទួលបានការអនុញ្ញាតពីបុគ្គលជានាឆ្លងកាត់គយ។

២- បុគ្គលជានាឆ្លងកាត់គយត្រូវបានតម្រូវដូចខាងក្រោម៖

ក- ត្រូវបង្ហាញនូវទំនិញដែលគ្មានការខូចខាត ដោយភ្ជាប់ជូននូវសំណុំឯកសារចាំបាច់មួយចំនួនទៅកាន់ការិយាល័យគយគម្យដ្ឋាននៅក្នុងអំឡុងពេលកំណត់ណាមួយ លុះត្រាតែមានការអនុញ្ញាតបញ្ចប់នីតិវិធីប្រព័ន្ធឆ្លងកាត់គយអាស៊ាននៅទីតាំងអាជីវកម្មរបស់ធុរជនដែលមានចែងក្នុងមាត្រា៤១នៃឧបសម្ព័ន្ធនេះ

ខ- ត្រូវបង្ហាញនូវរាល់ឯកសារនិងព័ត៌មានផ្សេងទៀតដែលពាក់ព័ន្ធនឹងប្រតិបត្តិការឆ្លងកាត់ ទៅកាន់អាជ្ញាធរមានសមត្ថកិច្ចដោយអនុលោមតាមការសំណើសុំក្នុងរយៈពេលកំណត់ដែលបានចែង និង

គ- ត្រូវពិនិត្យនូវបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងប្រព័ន្ធឆ្លងកាត់គយអាស៊ាន

៣- កថាខណ្ឌ១និងកថាខណ្ឌ២នៃមាត្រានេះ ត្រូវអនុវត្តចំពោះក្រុមហ៊ុនដឹកជញ្ជូនឬរូបវន្តបុគ្គល ឬនីតិបុគ្គលដែលទទួលយកទំនិញនិងដឹងថាទំនិញទាំងអស់នេះត្រូវដឹកជញ្ជូនក្រោមនីតិវិធីឆ្លងកាត់គយអាស៊ាន។

**មាត្រា៣.- ការកិបត្រាគយឬសៀលគយ**

១- នៅក្នុងវិធានទូទៅ ទំនិញឆ្លងកាត់នឹងត្រូវបានធានាដោយការកិបត្រាគយឬសៀលគយ៖

ក- កន្លែងដែលផ្ទុកទំនិញ នៅពេលដែលមធ្យោបាយដឹកជញ្ជូនត្រូវបានអនុម័ត ដោយអាជ្ញាធរមានសមត្ថកិច្ចដោយអនុលោមតាមបទប្បញ្ញត្តិពាក់ព័ន្ធនិង/ឬ មធ្យោបាយដឹកជញ្ជូនទាំងនេះត្រូវទទួលស្គាល់ដោយការិយាល័យគយដើមទី ថាសមស្របសម្រាប់ការកិបត្រាគយឬសៀលគយ ឬ

ខ- កញ្ចប់ទំនិញនីមួយៗក្នុងកេសផ្សេងៗគ្នា ។

២- មធ្យោបាយដឹកជញ្ជូនដែលត្រូវទទួលស្គាល់ថាសមស្របអាចកិបត្រាគយឬសៀលគយ ប្រសិនបើ៖

ក- អាចកិបត្រាគយឬសៀលគយដោយងាយស្រួលនិងមានប្រសិទ្ធភាព

ខ- គ្មានទំនិញណាអាចយកចេញឬដាក់ចូលក្នុងផ្នែកដែលបានកិបត្រាគយឬសៀលគយហើយ ដោយពុំមានបន្សល់ឲ្យឃើញនូវស្លាក់ស្នាមនៃការខូចខាតឬដោយពុំមាន ស្លាកស្នាមនៃការផ្តាច់ត្រាគយឬសៀលគយឡើយ

គ- ពុំមានកន្លែងចន្លោះទំនេរដែលអាចលាក់ទំនិញបាន

ឃ- កន្លែងដែលបម្រុងសម្រាប់ផ្ទុកទំនិញ ត្រូវអាចចូលត្រួតពិនិត្យបានយ៉ាងងាយស្រួល ដោយអាជ្ញាធរមានសមត្ថកិច្ច។

៣- ការិយាល័យគយដើមទីអាចលើកលែងនូវតម្រូវការសម្រាប់កិបត្រាគយឬសៀលគយ ក្នុងករណីដែលស្ថានភាពទំនិញដែលត្រូវដឹកជញ្ជូនមានលក្ខណៈពិបាកក្នុងការអនុវត្ត ប៉ុន្តែការ បរិយាយនៃទំនិញទាំងនេះមានលក្ខណៈគ្រប់គ្រាន់ ដែលងាយស្រួលក្នុងការកំណត់យថាប្រភេទ ទំនិញ។

## ផ្នែកទី២
## ការប្រើប្រាស់ព័ត៌មានវិទ្យា

**មាត្រា៤.- ការអនុវត្តនៃការផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកសម្រាប់ការ សម្របសម្រួលទំនិញឆ្លងកាត់**

១- ដោយគ្មានការប៉ះពាល់ដល់កាលៈទេសៈពិសេសណាមួយដូចមានចែងក្នុងកថាខណ្ឌ២ មាត្រា៣២នៃឧបសម្ព័ន្ធនេះ អាជ្ញាធរមានសមត្ថកិច្ចនៃភាគីហត្ថលេខីត្រូវប្រើព័ត៌មានវិទ្យា

ដើម្បីគ្រប់គ្រងហានិភ័យនិងចុះបញ្ជីពិនិត្យ តាមដាន និងផ្លាស់ប្តូរទិន្នន័យដែលពាក់ព័ន្ធនឹងនីតិវិធីនៃប្រព័ន្ធឆ្លងកាត់គយអាស៊ាន។

២- ដោយអនុលោមតាមកថាខណ្ឌ១នៃមាត្រានេះ ប្រព័ន្ធដែលត្រូវបានអនុម័ត ត្រូវរួមបញ្ចូលនូវវិធានការសម្រាប់ពិនិត្យពីប្រភពភាពត្រឹមត្រូវនិងសុចរិតភាពនៃទិន្នន័យនិងការពារទិន្នន័យទាំងនោះ ក្នុងហេតុការចែងដន្យណាមួយឬការបំផ្លាញដោយខុសច្បាប់ ឬការបាត់បង់ ដាយថាហេតុការកែសម្រួលឬការចូលទៅកាន់ទិន្នន័យដោយគ្មានការអនុញ្ញាត។

៣- អាជ្ញាធរមានសមត្ថកិច្ចត្រូវបង្កើតនិងរក្សាប្រកបដោយសុវត្ថិភាពគ្រប់គ្រាន់ក្នុងប្រតិបត្តិការប្រព័ន្ធកុំព្យូទ័រ សម្រាប់ប្រព័ន្ធឆ្លងកាត់គយអាស៊ានឲ្យមានប្រសិទ្ធភាព សុវត្ថិភាព និងភាពជឿទុកចិត្ត ។

**មាត្រា៥.- ស្តង់ដាសារអេឡិចត្រូនិកសម្រាប់ត្រួតពិនិត្យប្រតិបត្តិការឆ្លងកាត់**

១- សម្រាប់ការបញ្ចេញទំនិញពីគយ ការិយាល័យគយដើមទីត្រូវបញ្ជូនព័ត៌មានលម្អិតពាក់ព័ន្ធនឹងប្រតិវេទន៍ទំនិញឆ្លងកាត់គយអាស៊ាន ទៅឲ្យការិយាល័យគយគម្យដ្ឋាន ដោយប្រើប្រាស់សារអេឡិចត្រូនិកស្តីពី "កំណត់ត្រាការមកដល់ទំនិញដោយប៉ាន់ស្មាន" និងទៅឲ្យការិយាល័យគយឆ្លងកាត់នីមួយៗដោយប្រើប្រាស់សារអេឡិចត្រូនិកស្តីពី "កំណត់ត្រាទំនិញឆ្លងកាត់ដោយប៉ាន់ស្មាន" ។

២- ការិយាល័យគយឆ្លងកាត់ត្រូវកត់ត្រានូវទំនិញឆ្លងកាត់ ដោយផ្ទៀងផ្ទាត់ជាមួយសារអេឡិចត្រូនិកស្តីពី "កំណត់ត្រាទំនិញឆ្លងកាត់ដោយប៉ាន់ស្មាន" ដែលទទួលពីការិយាល័យគយដើមទី។ ការឆ្លងកាត់ទំនិញត្រូវជូនដំណឹងទៅឲ្យការិយាល័យគយដើមទីដោយប្រើប្រាស់សារអេឡិចត្រូនិកស្តីពី "ការជូនដំណឹងការឆ្លងកាត់ព្រំដែន" ។ ការិយាល័យគយឆ្លងកាត់ក៏អាចប្រើប្រាស់នូវសេចក្តីជូនដំណឹងនេះដើម្បីផ្ទៀងផ្ទាត់ថាតើទំនិញនេះបានត្រូវស្ថិតក្រោមការត្រួតពិនិត្យគយជាបន្តបន្ទាប់ដែរឬទេ ។

៣- ការិយាល័យគយគម្យដ្ឋាន ត្រូវប្រើប្រាស់សារអេឡិចត្រូនិកស្តីពី "សេចក្តីជូនដំណឹងការមកដល់ទំនិញ" ដើម្បីជូនដំណឹងទៅឲ្យការិយាល័យគយដើមទី ពីការមកដល់នៃទំនិញ។ សារអេឡិចត្រូនិកនេះត្រូវបញ្ជូនមិនឲ្យយូរជាងថ្ងៃបន្ទាប់ ក្រោយពីទំនិញបានមកដល់ការិយាល័យគយគម្យដ្ឋាន។ ការិយាល័យគយគម្យដ្ឋានអាចរក្សាទុកច្បាប់ចតចម្លងមួយច្បាប់នៃឯកសារអមការឆ្លងកាត់ ប្រសិនបើចាំបាច់។

៤- នៅពេលប្រតិបត្តិការឆ្លងកាត់បញ្ចប់នៅទីតាំងអាជីវកម្មរបស់ធុរជនដោយអនុលោមតាមការអនុញ្ញាតដែលមានចែងក្នុងមាត្រា៤១នៃឧបសម្ព័ន្ធនេះ ការិយាល័យគយគម្យដ្ឋានពាក់ព័ន្ធ ត្រូវបានផ្តល់ដំណឹងពីការមកដល់នៃទំនិញឲ្យបានមុនពេលទំនិញទាំងនេះត្រូវបាននាំចេញ។

៥- នៅពេលដែលការិយាល័យនិមុត្តិធានានិងការិយាល័យគយដើមទី ស្ថិតនៅដែនខុសគ្នានៃភាគីហត្ថលេខី សារដែលត្រូវប្រើប្រាស់សម្រាប់ផ្លាស់ប្តូរទិន្នន័យនិមុត្តិធានា ត្រូវកំណត់ការព្រមព្រៀងគ្នារវាងភាគីហត្ថលេខី។

៦- លើកលែងតែមានការផ្តល់ហេតុផលផ្សេង ការិយាល័យគយគម្យដ្ឋានត្រូវបញ្ជូនសារអេឡិចត្រូនិកស្តីពី "លទ្ធផលនៃការត្រួតពិនិត្យ" ទៅឲ្យការិយាល័យគយដើមទីមិនយូរជាងពីរថ្ងៃ បន្ទាប់ពីទំនិញត្រូវបញ្ជូនមកដល់ការិយាល័យគយគម្យដ្ឋាន។

## ផ្នែកទី៣
## និមុត្តិធានា

**មាត្រា៦.- ទូទៅ**

១- បុគ្គលជានាឆ្លងកាត់គយត្រូវតម្កល់និមុត្តិធានាសម្រាប់ធ្វើការទូទាត់បំណុលគយដែលអាចកើតឡើងក្រោមនីតិវិធីប្រព័ន្ធឆ្លងកាត់គយអាស៊ាន លើកលែងតែមានការផ្តល់ការលើកលែងនិមុត្តិធានា ដោយអនុលោមតាមកថាខណ្ឌ៨នៃមាត្រា១១ នៃឧបសម្ព័ន្ធនេះ។

២- ទាំងនេះអាចជា ៖

- ក- និមុត្តិធានាសម្រាប់ចរាចរទំនិញតែមួយលើក ដែលគ្របដណ្តប់តែប្រតិបត្តិការឆ្លងកាត់តែមួយលើក ឬ
- ខ- និមុត្តិធានាសម្រាប់ចរាចរទំនិញច្រើនលើក ដែលគ្របដណ្តប់ប្រតិបត្តិការឆ្លងកាត់ច្រើនលើក។

៣- អ្នកជានាត្រូវបង្កើតឡើងក្នុងដែនរបស់ភាគីហត្ថលេខីដែលនិមុត្តិធានាត្រូវតម្កល់ និងត្រូវទទួលការយល់ព្រមដោយការិយាល័យនិមុត្តិធានា។ អ្នកជានាត្រូវបង្ហាញអាសយដ្ឋានផ្តល់សេវាក្នុងដែនរបស់ភាគីហត្ថលេខីនីមួយៗដែលពាក់ព័ន្ធនឹងប្រតិបត្តិការឆ្លងកាត់។ ក្នុងករណីដែលអ្នកជានាគ្មានអាសយដ្ឋានផ្តល់សេវា អ្នកជានាត្រូវចាត់តាំងភ្នាក់ងារក្នុងដែនរបស់ភាគីហត្ថលេខីនីមួយៗដែលពាក់ព័ន្ធប្រតិបត្តិការឆ្លងកាត់។

៤- ការិយាល័យនិមុត្តិធានាត្រូវបដិសេធក្នុងការយល់ព្រមចំពោះអ្នកជានាដែលមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទូទាត់បំណុលគយក្នុងរយៈពេលកំណត់ ដែលបំណុលទាំងនេះអាចកើនដល់ចំនួនអតិបរមានៃនិមុត្តិធានា។

៥- និមុត្តិជានាសម្រាប់ចរាចរទំនិញមួយលើកត្រូវអនុលោមតាមទ្រង់ទ្រាយដែលព្រមព្រៀងដោយភាគីហត្ថលេខី។

៦- និមុត្តិជានាសម្រាប់ចរាចរទំនិញច្រើនលើកត្រូវអនុលោមតាមទ្រង់ទ្រាយដែលព្រមព្រៀងដោយភាគីហត្ថលេខី។

៧- ការទទួលខុសត្រូវរបស់អ្នកធានា ត្រូវផ្អែកលើការទទួលយកនិមុត្តិជានារបស់ខ្លួនដោយការិយាល័យនិមុត្តិជានា។ ប្រតិបត្តិការនេះនឹងមានប្រសិទ្ធភាពចាប់ពីកាលបរិច្ឆេទដែលការិយាល័យគយដើមទីទទួលយកប្រតិវេទន៍គយឆ្លងកាត់ ដែលអ្នកធានាធ្វើការធានា។

៨- ក្នុងករណីនិមុត្តិជានាសម្រាប់ចរាចរទំនិញមួយលើកឬច្រើនលើកការទទួលខុសត្រូវរបស់អ្នកធានាគឺមានដែនកំណត់ត្រឹមទឹកប្រាក់អតិបរមាដែលបង្ហាញក្នុងនិមុត្តិជានា។

៩- ការិយាល័យនិមុត្តិជានាត្រូវរក្សាភស្តុតាងពីការទទួលនិមុត្តិជានាពីអ្នកធានានិងត្រូវផ្តល់ភស្តុតាងនេះក្នុងទម្រង់អេឡិចត្រូនិកទៅឲ្យការិយាល័យគយដើមទីតាមការស្នើសុំ។

១០- ប្រសិនបើលក្ខខណ្ឌដែលដាក់ចេញមិនត្រូវបានបំពេញ ការិយាល័យនិមុត្តិជានាត្រូវលុបចោលការទទួលយកនិមុត្តិជានារបស់អ្នកធានា។

១១- ភាគីហត្ថលេខីទាំងអស់ត្រូវអនុញ្ញាតឲ្យលើកឡើងពីការព្រួយបារម្ភរបស់ខ្លួនពាក់ព័ន្ធនឹងសមត្ថភាពរបស់អ្នកធានាដើម្បីបំពេញការទាមទារនិងផ្តល់ហេតុផលទៅឲ្យការិយាល័យនិមុត្តិជានាពាក់ព័ន្ធ ដោយផ្អែកលើហេតុផលដែលអ្នកធានាអាចត្រូវលុបចោល។

## មាត្រា៧.- និមុត្តិធានាសម្រាប់ចរាចរទំនិញមួយលើក

១- និមុត្តិជានាសម្រាប់ចរាចរទំនិញមួយលើក ត្រូវគ្របដណ្តប់បំណុលគយដែលអាចកើតឡើងក្នុងប្រតិបត្តិការឆ្លងកាត់ពាក់ព័ន្ធ ដោយត្រូវគណនាលើមូលដ្ឋានអត្រាពន្ធនិងអាករខ្ពស់បំផុតនិងកម្រៃសេវាផ្សេងៗសម្រាប់ទំនិញក្នុងដែនដែលគ្របដណ្តប់ដោយប្រតិបត្តិការឆ្លងកាត់។

២- និមុត្តិជានាសម្រាប់ចរាចរទំនិញមួយលើក ត្រូវតម្កល់ក្នុងទម្រង់ដូចខាងក្រោម៖

ក- ប្រាក់តម្កល់នៅការិយាល័យនិមុត្តិជានា

ខ- លិខិតនិមុត្តិជានាដែលចេញទៅឲ្យបុគ្គលជានាឆ្លងកាត់គយ ដោយអ្នកជានា ឬ

គ- និមុត្តិជានាដែលផ្តល់ដោយអ្នកជានា

ទម្រង់នៃការទទួលយកនិមុត្តិជានា ត្រូវកំណត់ដោយការិយាល័យនិមុត្តិជានាក្នុងដែនរបស់ភាគីហត្ថលេខី ដែលការិយាល័យដើមទីស្ថិតនៅ ។

**មាត្រា៨.- ប្រាក់តម្កល់**

១- តម្លៃប្រាក់តម្កល់ត្រូវសមមូលនឹងតម្លៃសរុបនៃបំណុលគយដែលអាចកើតឡើង។

២- ប្រាក់តម្កល់ត្រូវជារូបិយវត្ថុរបស់ប្រទេសដើមទីឬជាមធ្យោបាយទូទាត់ណាមួយ ដែលទទួលស្គាល់ដោយការិយាល័យនិមុត្តិជានានៃប្រទេសដើមទីនិងអនុលោមតាមបញ្ញត្តិជាធរមានរបស់ប្រទេសដើមទី។

៣- និមុត្តិជានាសម្រាប់ចរាចរទំនិញតែមួយលើកក្នុងទម្រង់ប្រាក់តម្កល់ ត្រូវមានសុពលភាពគ្រប់ភាគីហត្ថលេខីទាំងអស់។

៤- ប្រាក់តម្កល់ត្រូវបង្វែរសងវិញដោយការិយាល័យនិមុត្តិជានា នៅពេលដែលប្រតិបត្តិការឆ្លងកាត់ត្រូវបញ្ចប់។

**មាត្រា៩.- លិខិតនិមុត្តិធានាសម្រាប់ចរាចរទំនិញមួយលើក**

១- បុគ្គលជានាឆ្លងកាត់គយអាចប្រើប្រាស់លិខិតនិមុត្តិជានាសម្រាប់ចរាចរទំនិញតែមួយលើក ដែលចេញដោយអ្នកជានា។

២- បុគ្គលជានាឆ្លងកាត់គយអាចផ្តល់លិខិតនិមុត្តិជានាសម្រាប់ចរាចរទំនិញមួយលើក ដែលមានតម្លៃស្មើនឹងបំណុលគយសរុបដែលអាចកើតឡើង ទៅឲ្យការិយាល័យនិមុត្តិជានា។

៣- អ្នកជានាត្រូវបង្ហាញលើលិខិតនិមុត្តិជានាសម្រាប់ចរាចរទំនិញតែមួយលើកនូវដែនរបស់ភាគីហត្ថលេខីដែលលិខិតនិមុត្តិជានានេះមានសុពលភាព រយៈពេលសុពលភាព កាលបរិច្ឆេទផុតកំណត់នៃការប្រើលិខិតនិមុត្តិជានានេះ ដែលមិនត្រូវលើសពី៩០ថ្ងៃគិតចាប់ពីថ្ងៃចេញ។

៤- ប្រសិនការិយាល័យគយដើមទីទទួលលិខិតនិមុត្តិជានានៅថ្ងៃឬមុនថ្ងៃផុតកំណត់នៃការប្រើលិខិតនិមុត្តិជានា លិខិតនិមុត្តិជានានេះត្រូវមានសុពលភាពរហូតដល់ប្រតិបត្តិការឆ្លងកាត់ត្រូវបញ្ចប់។

៥- លិខិតនិមុត្តិជានាសម្រាប់ចរាចរទំនិញតែមួយលើក ត្រូវមានលេខរៀងមិនជាន់គ្នា និងអនុលោមតាមទម្រង់ដែលព្រមព្រៀងគ្នាដោយភាគីហត្ថលេខី។

៦- អ្នកជានាត្រូវផ្តល់ព័ត៌មានលម្អិតនៃលិខិតនិមុត្តិជានាដែលចេញទៅឲ្យការិយាល័យនិមុត្តិជានា។

**មាត្រា១០.- ការប្រើប្រាស់និមុត្តិធានាសម្រាប់ចរាចរទំនិញតែមួយលើក**

១- អ្នកជានាអាចផ្តល់និមុត្តិជានាសម្រាប់ចរាចរទំនិញតែមួយលើក ដើម្បីជានាប្រតិបត្តិការឆ្លងកាត់គយមួយលើក។

២- និមុត្តិជានាសម្រាប់ចរាចរទំនិញតែមួយលើកត្រូវអនុលោមតាមទម្រង់ដែលបានឯកភាពដោយភាគីហត្ថលេខីនិងត្រូវមានឈ្មោះបុគ្គលជានាឆ្លងកាត់គនិងតម្លៃនៃនិមុត្តិជានាត្រូវស្មើនឹងតម្លៃបំណុលគយសរុបដែលអាចកើតឡើង។

៣- និមុត្តិជានានីមួយៗសម្រាប់ចរាចរទំនិញតែមួយលើកត្រូវតម្កល់នៅការិយាល័យនិមុត្តិជានានិងច្បាប់ចម្លងនៃនិមុត្តិជានាមួយច្បាប់ នឹងត្រូវរក្សាទុកនៅការិយាល័យគយដើមទី។

នៅពេលបញ្ចប់ប្រតិបត្តិការឆ្លងកាត់គយ និមុត្តិជានាសម្រាប់ចរាចរទំនិញតែមួយលើកនឹងត្រូវលុបចោលនិងអ្នកជានាត្រូវបានជូនដំណឹងអំពីការលុបចោលនេះ។

## មាត្រា១១.- និមុត្តិជានាសម្រាប់ចរាចរទំនិញច្រើនលើក

១- បុគ្គលជានាឆ្លងកាត់គយអាចប្រើប្រាស់និមុត្តិជានាសម្រាប់ចរាចរទំនិញច្រើនលើកដោយផ្អែកលើតម្លៃយោង។ តម្លៃយោងត្រូវស្មើនឹងតម្លៃបំណុលគយសរុបដែលអាចកើតឡើងពាក់ព័ន្ធនឹងទំនិញដែលបុគ្គលជានាឆ្លងកាត់គយ ដាក់ក្រោមនីតិវិធីប្រព័ន្ធឆ្លងកាត់គយអាស៊ានសម្រាប់រយៈពេលយ៉ាងតិចប្រាំពីរថ្ងៃ។

២- ការិយាល័យនិមុត្តិជានាពាក់ព័ន្ធត្រូវបង្កើតតម្លៃយោង ដោយសហការជាមួយបុគ្គលជានាឆ្លងកាត់គយ ដោយពិចារណាលើ៖

ក- ព័ត៌មានទំនិញដែលបុគ្គលជានាឆ្លងកាត់គយបានដាក់ក្រោមនីតិវិធីប្រព័ន្ធឆ្លងកាត់គយអាស៊ាននាពេលកន្លងមកនិង/ឬការប៉ាន់ប្រមាណនៃបរិមាណទំនិញនិងតម្លៃទំនិញដែលត្រូវដាក់នៅក្រោមនីតិវិធីប្រព័ន្ធឆ្លងកាត់គយអាស៊ាន។

ខ- អត្រាពន្ធនិងអាករខ្ពស់បំផុតនិងកម្រៃសេវាផ្សេងទៀតដែលអនុវត្តក្នុងប្រទេសឆ្លងកាត់។

៣- ការិយាល័យនិមុត្តិជានាត្រូវពិនិត្យឡើងវិញនូវតម្លៃយោងយ៉ាងតិចមួយឆ្នាំម្តង ដោយប្រើប្រាស់ព័ត៌មានទទួលបានពីការិយាល័យគយដើមទីនិងត្រូវធ្វើការកែតម្រូវប្រសិនចាំបាច់។

៤- បុគ្គលជានាឆ្លងកាត់គយត្រូវជូនដំណឹងទៅការិយាល័យនិមុត្តិជានា ប្រសិនបើតម្លៃយោងទាបជាងតម្លៃដែលត្រូវគ្របដណ្តប់សម្រាប់ជានាប្រតិបត្តិការឆ្លងកាត់គយបច្ចុប្បន្នឬប្រតិបត្តិការឆ្លងកាត់គយដែលគ្រោងអនាគត។

៥- តម្លៃដែលត្រូវគ្របដណ្តប់ដោយនិមុត្តិជានាសម្រាប់ចរាចរទំនិញច្រើនលើកត្រូវស្មើនឹងតម្លៃយោង ដោយអនុលោមតាមកថាខណ្ឌ១នៃមាត្រានេះ។

៦- បុគ្គលជានាឆ្លងកាត់គយដែលបំពេញលក្ខណវិនិច្ឆ័យពាក់ព័ន្ធនឹងបទពិសោធន៍ភាពជឿទុកចិត្ត និងស្ថានភាពហិរញ្ញវត្ថុ អាចត្រូវអនុញ្ញាតឲ្យផ្តល់នូវនិមុត្តិជានាសម្រាប់តម្លៃ

តិចជាងមុនឬមិនតម្រូវឲ្យតម្កល់និមុត្តិធានា  ប៉ុន្តែជាកម្មវត្ថុនៃកិច្ចព្រមព្រៀងរវាងភាគីហត្ថលេខី ពាក់ព័ន្ធនឹងប្រតិបត្តិការឆ្លងកាត់គយ។

៧- តម្លៃនិមុត្តិធានាដែលតម្រូវ អាចត្រូវកាត់បន្ថយ

ក- ៥០% នៃតម្លៃយោង ក្នុងករណីបុគ្គលធានាឆ្លងកាត់គយបង្ហាញថា មានបទពិសោធគ្រប់គ្រាន់ពាក់ព័ន្ធនឹងនីតិវិធីគយ ឬ

ខ- ២៥% នៃតម្លៃយោង ក្នុងករណីបុគ្គលធានាឆ្លងកាត់គយបង្ហាញថា មានបទពិសោធគ្រប់គ្រាន់ពាក់ព័ន្ធនឹងនីតិវិធីគយនិងសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមានសមត្ថកិច្ច។

៨- ការមិនតម្រូវឲ្យតម្កល់និមុត្តិធានាអាចត្រូវផ្តល់ជូន ក្នុងករណីបុគ្គលធានាឆ្លងកាត់គយបង្ហាញថា អាចបំពេញលក្ខណវិនិច្ឆ័យដែលមានចែងក្នុងមាត្រា១៥នៃឧបសម្ព័ន្ធនេះនិងអាចគ្រប់គ្រងប្រតិបត្តិការដឹកជញ្ជូន និងមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួន។

៩- ក្នុងការអនុវត្តកថាខណ្ឌខាងលើ ភាគីហត្ថលេខីទាំងអស់ត្រូវពិចារណាលើ៖

ក- ព័ត៌មានដែលផ្តល់ដោយបុគ្គលធានាឆ្លងកាត់គយនៅក្នុងពាក្យស្នើសុំក្នុងទម្រង់ដែលបានឯកភាពដោយភាគីហត្ថលេខី និង

ខ- យោបល់ណាមួយដែលទទួលបានពីភាគីហត្ថលេខីផ្សេងទៀត ដូចមានចែងក្នុងកថាខណ្ឌ៧ នៃមាត្រា១៦នៃឧបសម្ព័ន្ធនេះ។

## មាត្រា១២.- ការប្រើប្រាស់និមុត្តិធានាសម្រាប់ចរាចរទំនិញច្រើនលើក

១- និមុត្តិធានាសម្រាប់ចរាចរទំនិញច្រើនលើក ត្រូវចេញដោយអ្នកធានា។

២- ការិយាល័យនិមុត្តិធានាត្រូវចេញឲ្យបុគ្គលធានាឆ្លងកាត់គយ នូវវិញ្ញាបនបត្រនិមុត្តិធានាសម្រាប់ចរាចរទំនិញច្រើនដងចំនួនមួយឬច្រើន  ដែលអនុលោមតាមទម្រង់ឯកភាពដោយភាគីហត្ថលេខី ដើម្បីទុកជាភស្តុតាងថា គាត់កាន់កាប់និមុត្តិធានាសម្រាប់ចរាចរទំនិញច្រើនលើក ។

៣- ក្នុងករណីទិន្នន័យនិមុត្តិធានាត្រូវផ្លាស់ប្តូររវាងការិយាល័យនិមុត្តិធានានិងការិយាល័យគយដើមទីតាមរយៈបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍  វិញ្ញាបនបត្រនិមុត្តិធានាត្រូវបញ្ចូលទៅក្នុងប្រតិវេទន៍ឆ្លងកាត់គយនិងត្រូវបោះពុម្ពនៅលើឯកសារអមការដឹកជញ្ជូនឆ្លងកាត់គយ។

៤- នៅពេលអវត្តមាននៃការផ្លាស់ប្តូរទិន្នន័យតាមទម្រង់អេឡិចត្រូនិក វិញ្ញាបនបត្រនិមុត្តិធានាត្រូវបង្ហាញដល់ការិយាល័យគយដើមទីដោយបុគ្គលធានាឆ្លងកាត់គយ។

**មាត្រា១៣.- ភារទទួលខុសត្រូវរបស់អ្នកធានា**

១- អ្នកធានាត្រូវទូទាត់បំណុលគយ ដោយអនុលោមតាមច្បាប់គយ ច្បាប់ពាក់ព័ន្ធផ្សេងទៀត និងបទប្បញ្ញត្តិនៃភាគីហត្ថលេខី នៅពេលភាពមិនប្រក្រតីត្រូវរកឃើញពាក់ព័ន្ធនឹងប្រតិបត្តិការឆ្លងកាត់គយ។ អ្នកធានាត្រូវទទួលខុសត្រូវរួមគ្នាជាមួយបុគ្គលធានាឆ្លងកាត់គយក្នុងការទូទាត់សងបំណុលនេះ។

២- ការទទួលខុសត្រូវរបស់អ្នកធានាត្រូវចាប់ផ្តើមនៅពេលប្រតិវេទន៍គយឆ្លងកាត់ដែលធានាត្រូវទទួលយកដោយការិយាល័យគយដើមទីនិងអាជ្ញាធរមានសមត្ថកិច្ចនៃភាគីហត្ថលេខីនោះ។ អ្នកធានាត្រូវទទួលខុសត្រូវដោយស្វ័យប្រវត្តិចំពោះអាជ្ញាធរមានសមត្ថកិច្ចនៃភាគីហត្ថលេខីបន្ទាប់នីមួយៗ នៅពេលដែលទំនិញចូលទៅក្នុងដែនរបស់ភាគីហត្ថលេខីបន្ទាប់នោះ។

៣- អនុលោមតាមកថាខណ្ឌ៨ នៃមាត្រា៦ នៃឧបសម្ព័ន្ធនេះ ការទទួលខុសត្រូវរបស់អ្នកធានាត្រូវគ្របដណ្តប់មិនត្រឹមតែទំនិញដែលបញ្ចូលនៅក្នុងប្រតិវេទន៍គយឆ្លងកាត់ ប៉ុន្តែថែមទាំងរាប់បញ្ចូលទំនិញស្របច្បាប់ផ្សេងទៀតដែលអាចត្រូវផ្ទុកនៅក្នុងកន្លែងផ្ទុកឥវ៉ាន់របស់យានយន្ត ឬកុងតឺន័រហើយគួរត្រូវបានប្រកាស។ វាមិនត្រូវពង្រីកដល់ទំនិញផ្សេងទៀត។

៤- ក្នុងករណីប្រតិបត្តិការឆ្លងកាត់គយមិនទាន់បញ្ចប់ និងភាពមិនប្រក្រតីត្រូវបានរកឃើញ អាជ្ញាធរមានសមត្ថកិច្ចនៃភាគីហត្ថលេខីត្រូវ៖

- ក- ក្នុងរយៈពេលកៅសិបថ្ងៃគិតចាប់ពីកាលបរិច្ឆេទដែលប្រតិវេទន៍គយឆ្លងកាត់ ត្រូវបានទទួលយកដោយការិយាល័យគយដើមទជូនដំណឹងដល់អ្នកធានាថានីតិវិធីមិនទាន់បានបញ្ចប់ និង
- ខ- ក្នុងរយៈពេលពីររយចិតសិបថ្ងៃគិតចាប់ពីកាលបរិច្ឆេទដែលប្រតិវេទន៍គយឆ្លងកាតត្រូវទទួលយកដោយការិយាល័យគយដើមទីជូនដំណឹងដល់អ្នកធានាថាត្រូវ ឬអាចតម្រូវឲ្យទូទាត់បំណុលគយដែលគាត់ទទួលខុសត្រូវក្នុងនាមជាអ្នកធានាចំពោះប្រតិបត្តិការដឹកជញ្ជូន។ សេចក្តីជូនដំណឹងត្រូវមាន៖
  - (i) លេខបញ្ជីកានិងកាលបរិច្ឆេទនៃប្រតិវេទន៍គយឆ្លងកាត់
  - (ii) ឈ្មោះការិយាល័យគយដើមទី
  - (iii) ឈ្មោះនិងអាសយដ្ឋានរបស់បុគ្គលធានាឆ្លងកាត់គយ និង
  - (iv) ទឹកប្រាក់ដែលត្រូវទូទាត់។

៥- អ្នកធានាត្រូវអនុញ្ញាតឲ្យរួចផុតពីកាតព្វកិច្ចរបស់ខ្លួនដែលតម្រូវដោយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនឹងប្រតិបត្តិការឆ្លងកាត់គយ ប្រសិនសេចក្តីជូនដំណឹងណាមួយដែលមានចែង

ក្នុងកថាខណ្ឌ៤ នៃមាត្រានេះ មិនត្រូវបានចេញជាលាយលក្ខណ៍អក្សរដល់អ្នកជានា មុនពេលផុតកំណត់នៃពេលវេលាកំណត់ពាក់ព័ន្ធ។

៦- ក្នុងករណីសេចក្តីជូនដំណឹងត្រូវបានចេញអនុលោមតាមកថាខណ្ឌ៤នៃមាត្រានេះ ការិយាល័យនិមុត្តិជានាត្រូវជូនដំណឹងអ្នកជានាពីការទូទាត់បំណុលគយឬការបញ្ចប់ប្រតិបត្តិការប្រព័ន្ធឆ្លងកាត់គយអាស៊ាន។

៧- នៅពេលអាជ្ញាធរមានសមត្ថកិច្ចនៃភាគីហត្ថលេខីបានបញ្ចប់ប្រតិបត្តិការប្រព័ន្ធឆ្លងកាត់គយអាស៊ាន អាជ្ញាធរមិនអាចទាមទារការទូទាត់ពីអ្នកជានាលុះត្រាតែមានព័ត៌មានក្លែងបន្លំក្នុងការបញ្ចប់ប្រតិបត្តិការឆ្លងកាត់គយ។

៨- ក្នុងករណីអ្នកជានាមិនត្រូវបានជូនដំណឹងអំពីការទាមទារទូទាត់ដែលកើតមានពីការបញ្ចប់ការឆ្លងកាត់គយក្លែងបន្លំក្នុងរយៈពេលមួយឆ្នាំគិតចាប់ពីថ្ងៃដែលប្រតិវេទន៍ឆ្លងកាត់គយពាក់ព័ន្ធត្រូវបានទទួលយកដោយអង្គភាពគយក្នុងប្រទេសដើមទី អ្នកជានាត្រូវអនុញ្ញាតឲ្យរួចផុតពីការទទួលខុសត្រូវទាំងអស់ពាក់ព័ន្ធនឹងការប្រតិបត្តិការឆ្លងកាត់គយនោះ។

៩- អ្នកជានាត្រូវមានរយៈពេលសាមសិបថ្ងៃចាប់ពីកាលបរិច្ឆេទដែលការទាមទារទូទាត់ជាលាយលក្ខអក្សរត្រូវផ្តល់ជូន។ ប្រាក់សរុបដែលបានទូទាត់ត្រូវប្រគល់ឲ្យអ្នកជានាវិញ ប្រសិនបើក្នុងរយៈពេលមួយឆ្នាំចាប់ពីកាលបរិច្ឆេទដែលការទាមទារប្រាក់ត្រូវបានទូទាត់ អ្នកជានាអាចបញ្ជាក់អាជ្ញាធរមានសមត្ថកិច្ចថា មិនមានភាពប្រក្រតីកើតឡើងពាក់ព័ន្ធនឹងប្រតិបត្តិការឆ្លងកាត់គយ។

## មាត្រា១៤.- ការលុបចោលនិងការដកហូតនិមុត្តិជានា

១- ការិយាល័យនិមុត្តិជានាត្រូវលុបចោលការទទួលយកនូវនិមុត្តិជានា ឬដកហូតការអនុញ្ញាតមិនតម្រូវឲ្យតម្កល់និមុត្តិជានារបស់បុគ្គលជានាឆ្លងកាត់គយ ប្រសិនបើលក្ខខណ្ឌដែលបានកំណត់នៅពេលចេញការទទួលយកនូវនិមុត្តិជានា ឬការអនុញ្ញាតមិនតម្រូវឲ្យតម្កល់និមុត្តិជានាមិនត្រូវបានបំពេញ។ ការលុបចោលឬដកហូតត្រូវចូលជាធរមានភ្លាម។

២- អ្នកជានាអាចលុបចោលនិមុត្តិជានារបស់ខ្លួននៅពេលណាមួយក៏បាន។ ការលុបចោលត្រូវធ្វើឡើងនៅថ្ងៃទីដប់បួនបន្ទាប់ពីកាលបរិច្ឆេទដែលសេចក្តីសម្រេចត្រូវបានជូនដំណឹងជាលាយលក្ខណ៍អក្សរទៅឲ្យការិយាល័យនិមុត្តិជានា។

៣- ការដកហូត ឬការលុបចោលត្រូវមិនប៉ះពាល់ដល់កាតព្វកិច្ចណាមួយដែលកើតឡើងពីលទ្ធផលនៃប្រតិបត្តិការឆ្លងកាត់គយដែលចាប់ផ្តើមមុនកាលបរិច្ឆេទនៃការដកហូត ឬការលុបចោលចូលជាធរមាន។

៤- ចាប់ពីកាលបរិច្ឆេទនៃការដកហូត ឬការលុបចូលជាធរមានរាល់វិញ្ញាបនបត្រនិមុត្តិជានាដែលចេញមុនកាលបរិច្ឆេទនេះ នឹងមិនមានសុពលភាពសម្រាប់ប្រើដាក់ទំនិញនៅក្រោមនីតិវិធីប្រព័ន្ធឆ្លងកាត់គយអាស៊ាន ហើយបុគ្គលជានាឆ្លងកាត់គយ ត្រូវប្រគល់វិញ្ញាបនបត្រដែលខ្លួនកាន់កាប់ទៅឲ្យការិយាល័យនិមុត្តិជានាវិញដោយគ្មានការពន្យារពេល។

៥- ការិយាល័យនិមុត្តិជានាពាក់ព័ន្ធ ត្រូវជូនដំណឹងដល់ភាគីហត្ថលេខីនីមួយៗពីចំណាត់ការរបស់ខ្លួន អនុលោមតាមកថាខណ្ឌ១នៃមាត្រានេះទេ។

## ផ្នែកទី៤
## ធុរជនឆ្លងកាត់គយទទួលការអនុញ្ញាត

### មាត្រា១៥.- លក្ខណវិនិច្ឆ័យទូទៅ

១- ដើម្បីមានសិទ្ធិជាធុរជនឆ្លងកាត់គយទទួលការអនុញ្ញាតនិងប្រើប្រាស់នីតិវិធីសាមញ្ញលក្ខខណ្ឌទូទៅ ត្រូវបំពេញមានដូចខាងក្រោម៖

អ្នកស្នើសុំ៖

ក- ត្រូវមានការិយាល័យ ទីស្នាក់ការកណ្តាល ឬអាជីវកម្មអចិន្ត្រៃយ៍ដែលចុះបញ្ជីនៅក្នុងដែនរបស់ភាគីហត្ថលេខី ដែលសំណើសុំសិទ្ធិជាធុរជនឆ្លងកាត់គយទទួលការអនុញ្ញាតត្រូវបានធ្វើឡើង និង

ខ- ត្រូវប្រើនីតិវិធីប្រព័ន្ធឆ្លងកាត់គយអាស៊ានជាទៀងទាត់ឬក្នុងករណីសំណើសុំសិទ្ធិជាធុរជនឆ្លងកាត់គយទទួលការអនុញ្ញាតជាលើកដំបូង ត្រូវបង្ហាញនូវចេតនាក្នុងការប្រើនីតិវិធីប្រព័ន្ធឆ្លងកាត់គយអាស៊ានជាទៀងទាត់។

២- ដើម្បីជានាបាននូវការគ្រប់គ្រងឲ្យត្រឹមត្រូវនូវនីតិវិធីសាមញ្ញ ការផ្តល់សិទ្ធិអាចត្រូវផ្តល់ជូនតែចំពោះបុគ្គលពាក់ព័ន្ធណាដែលរក្សាទុកកំណត់ត្រា អាចអនុញ្ញាតឲ្យអាជ្ញាធរមានសមត្ថកិច្ចត្រួតពិនិត្យនីតិវិធីនិងអនុវត្តការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។

៣- ក្នុងការពិចារណាលើសំណើសុំអាជ្ញាធរមានសមត្ថកិច្ចត្រូវពិចារណាលើករណីបទល្មើសនានាពាក់ព័ន្ធនឹងច្បាប់គយឬពន្ធដារក្នុងរយៈពេលប្រាំឆ្នាំកន្លងមក។

**មាត្រា១៦.- សំណើសុំនិងសេចក្តីសម្រេចសម្រាប់ធុរជនឆ្លងកាត់គយទទួលការអនុញ្ញាត**

១- សំណើសុំសិទ្ធិជាធុរជនឆ្លងកាត់គយទទួលការអនុញ្ញាត ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរក្នុងទម្រង់ដែលឯកភាពគ្នាដោយភាគីហត្ថលេខីនិងត្រូវចុះហត្ថលេខានិងកាលបរិច្ឆេទ។ សំណើសុំត្រូវបញ្ជាក់ពីនីតិវិធីសាមញ្ញដែលធុរជនស្នើសុំ។

២- បុគ្គលដែលស្នើសុំសិទ្ធិជាធុរជនឆ្លងកាត់គយទទួលការអនុញ្ញាតនិងនីតិវិធីសាមញ្ញពាក់ព័ន្ធ ត្រូវទទួលខុសត្រូវៈ

ក- ភាពត្រឹមត្រូវនៃព័ត៌មានដែលផ្តល់ឲ្យ និង

ខ- យថាភូតនៃឯកសារដែលភ្ជាប់ជាមួយ។

ការផ្តល់សិទ្ធិជាធុរជនឆ្លងកាត់គយទទួលការអនុញ្ញាត ត្រូវដកហូតនិងចូលជាធរមានភ្លាម ប្រសិនរកឃើញព័ត៌មានក្លែងបន្លំនិងមិនត្រឹមត្រូវ។

៣- សំណើសុំត្រូវដាក់នៅអាជ្ញាធរមានសមត្ថកិច្ចនៃភាគីហត្ថលេខីដែលអ្នកស្នើសុំបានបង្កើតអាជីវកម្ម។ក្នុងករណីអ្នកស្នើសុំបង្កើតអាជីវកម្មក្នុងដែននៅក្នុងភាគីហត្ថលេខីច្រើនជាងមួយ អ្នកស្នើសុំអាចដាក់ពាក្យស្នើសុំនៅក្នុងដែនរបស់ភាគីហត្ថលេខីនីមួយៗ ប្រសិនបើមានបំណង។

៤- ការផ្តល់សិទ្ធិត្រូវផ្តល់និងសំណើសុំត្រូវប្រានចោលដោយអនុលោមតាមបទប្បញ្ញត្តិជាធរមានរបស់ភាគីហត្ថលេខី។

៥- សេចក្តីសម្រេចបដិសេធសំណើសុំទាំងមូលឬផ្នែកមួយឬច្រើននៃនីតិវិធីសាមញ្ញដែលស្នើសុំ ត្រូវសរសេរជាលាយលក្ខណ៍អក្សរនិងបញ្ជាក់ពីមូលហេតុនៃការបដិសេធ។

៦- ប្រសិនសំណើសុំមានព័ត៌មានគ្រប់គ្រាន់ សេចក្តីសម្រេចលើសំណើសុំត្រូវផ្តល់ជូនក្នុងរយៈពេលកៅសិបថ្ងៃចាប់ពីកាលបរិច្ឆេទនៃការទទួលពាក្យស្នើសុំដោយអាជ្ញាធរមានសមត្ថកិច្ច។

៧- សេចក្តីសម្រេចត្រូវជូនដំណឹងដល់ភាគីហត្ថលេខីផ្សេងទៀត។ សេចក្តីសម្រេចនេះត្រូវជាកម្មវត្ថុនៃការពិនិត្យឡើងវិញដោយភាគីហត្ថលេខីផ្សេងទៀត ដោយត្រូវផ្តល់យោបល់ក្នុងរយៈពេលមិនលើសពីសាមសិបថ្ងៃចាប់ពីថ្ងៃទទួលការជូនដំណឹង ដោយផ្អែកលើមូលដ្ឋានថាសេចក្តីសម្រេចអាចត្រូវកែប្រែឬរក្សាទុក។

**មាត្រា ១៧.- លិខិតអនុញ្ញាត**

១-បន្ទាប់ពីពាក្យស្នើសុំរបស់បុគ្គលជានាឆ្លងកាត់គយបំពេញលក្ខណវិនិច្ឆ័យដូចកំណត់ក្នុងមាត្រា១៥នៃឧបសម្ព័ន្ធនេះ អាជ្ញាធរមានសមត្ថកិច្ចអាចផ្តល់សិទ្ធិជាធុរជនឆ្លងកាត់គយទទួលការអនុញ្ញាត ដោយប្រើប្រាស់នីតិវិធីសាមញ្ញមួយឬច្រើន ដូចខាងក្រោមៈ

ក- ការប្រើប្រាស់និមុត្តិជានាសម្រាប់ចរាចរទំនិញច្រើនលើក

ខ- ការលើកលែងការតម្រូវក្នុងការបង្ហាញទំនិញនិងមធ្យោបាយដឹកជញ្ជូននៅការិយាល័យគយដើមទី

គ- ការប្រើប្រាស់ការកិបត្រាគយឬសៀលគយពិសេសដែលមានការអនុញ្ញាត និង

ឃ- ការប្រើនីតិវិធីសាមញ្ញផ្សេងទៀត ដែលកំណត់ដោយភាគីហត្ថលេខី។

២- លិខិតអនុញ្ញាតដែលផ្តល់ឲ្យប្រើនូវនីតិវិធីសាមញ្ញ ដែលចែងក្នុងកថាខណ្ឌ១(ក) នៃមាត្រានេះ ត្រូវអនុវត្តក្នុងដែនរបស់ភាគីហត្ថលេខីទាំងអស់ លើកលែងតែមានការអនុញ្ញាតផ្សេងពីនេះ។ នីតិវិធីសាមញ្ញក្នុងកថាខណ្ឌរង១(ខ)និង១(គ)នៃមាត្រានេះត្រូវអនុវត្តតែក្នុងប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់ដែលចាប់ផ្តើមពីដែនរបស់ភាគីហត្ថលេខីដែលផ្តល់លិខិតអនុញ្ញាតតែប៉ុណ្ណោះ។

៣- លិខិតអនុញ្ញាតដើមដែលចុះហត្ថលេខានិងកាលបរិច្ឆេទ និងលិខិតអនុញ្ញាតច្បាប់ចម្លងមួយឬច្រើន ត្រូវប្រគល់ជូនអ្នកកាន់កាប់លិខិតអនុញ្ញាត។

៤- លិខិតអនុញ្ញាតនេះត្រូវមានសុពលភាពចាប់ពីកាលបរិច្ឆេទដែលផ្តល់ ព្រមទាំងបញ្ជាក់លក្ខខណ្ឌពាក់ព័ន្ធនឹងការប្រើប្រាស់នីតិវិធីសាមញ្ញដែលបានផ្តល់។

## មាត្រា១៨.- វិសោធនកម្ម ការបោះបង់ ឬនិរាករណ៍លិខិតអនុញ្ញាត

១- អ្នកកាន់កាប់លិខិតអនុញ្ញាត ត្រូវជូនដំណឹងទៅអាជ្ញាធរមានសមត្ថកិច្ចពីកត្តាកើតឡើង ដែលអាចជះឥទ្ធិពលលើសុពលភាពឬខ្លឹមសាររបស់វា ក្រោយពេលលិខិតអនុញ្ញាតនេះត្រូវបានផ្តល់ជូន។

២- អាជ្ញាធរមានសមត្ថកិច្ចត្រូវដកហូត ឬ កែប្រែលិខិតអនុញ្ញាត នៅពេលដែលៈ

ក- អ្នកកាន់កាប់មានបំណងចង់បោះបង់សិទ្ធិអនុញ្ញាតរបស់ខ្លួន

ខ- មានខ្លឹមសារមួយឬច្រើននៃលិខិតអនុញ្ញាតដែលផ្តល់ឲ្យលែងមានសុពលភាព

គ- កត្តាកើតឡើង ដែលអាចជះឥទ្ធិពលលើការបន្តឬខ្លឹមសាររបស់វា ក្រោយពេលលិខិតអនុញ្ញាតនេះត្រូវបានផ្តល់ជូន ឬ

ឃ- អ្នកកាន់កាប់បរាជ័យក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនជាធុរជនឆ្លងកាត់ទទួលការអនុញ្ញាត ។

៣- ក្រៅពីការបោះបង់លិខិតអនុញ្ញាតដោយស្ម័គ្រចិត្ត អ្នកកាន់កាប់ត្រូវផ្តល់ការណែនាំជាលាយលក្ខណ៍អក្សរនូវហេតុផលនៃការសម្រេចចិត្តលើការធ្វើវិសោធនកម្មឬការដកហូតលិខិតអនុញ្ញាត។

៤- ការដកហូតឬការធ្វើវិសោធនកម្មលិខិតអនុញ្ញាត ត្រូវចូលជាធរមានចាប់ពីថ្ងៃដែលកំណត់ក្នុងសេចក្តីជូនដំណឹង។

## ផ្នែកទី៥
## នីតិវិធីសាមញ្ញ

**មាត្រា១៩.- ការលើកលែងការបង្ហាញទំនិញនៅការិយាល័យគយដើមទី**

១- បុគ្គលជានាឆ្លងកាត់គយ ដែលត្រូវបានផ្តល់សិទ្ធិជាធុរជនឆ្លងកាត់ទទួលការអនុញ្ញាតរួមទាំងសិទ្ធិប្រើប្រាស់និមុត្តិជានាសម្រាប់ចរាចរទំនិញច្រើនលើក អាចត្រូវអនុញ្ញាតឲ្យធ្វើប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់ដោយមិនតម្រូវឲ្យបង្ហាញទំនិញនិងបំពេញប្រតិវេទន៍គយឆ្លងកាត់នៅការិយាល័យគយដើមទី។ ការលើកលែងនេះក៏ត្រូវអនុវត្តចំពោះមធ្យោបាយដឹកជញ្ជូនទំនិញដែលពាក់ព័ន្ធផងដែរ។

២- មធ្យោបាយនេះត្រូវអនុញ្ញាតតែនៅពេលដែលបុគ្គលជានាឆ្លងកាត់គយតម្កល់ប្រតិវេទន៍គយឆ្លងកាត់ និងទំនាក់ទំនងមកការិយាល័យគយដើមទីដោយប្រើប្រាស់បច្ចេកទេសបញ្ជូនទិន្នន័យតាមទម្រង់អេឡិចត្រូនិក។

៣- ប្រតិវេទន៍គយឆ្លងកាត់ត្រូវតម្កល់នៅការិយាល័យគយដើមទី មុននឹងទំនិញត្រូវអនុញ្ញាតឲ្យយកចេញពីគយ។

៤- លិខិតអនុញ្ញាតត្រូវមានបញ្ជាក់ពីពេលវេលាកំណត់ដែលការិយាល័យគយដើមទីមានគោលបំណងដើម្បីអនុវត្តការត្រួតពិនិត្យ បន្ទាប់ពីពេលវេលានេះផុតកំណត់ ទំនិញត្រូវអនុញ្ញាតឲ្យយកចេញពីគយដោយស្វ័យប្រវត្តិ។

៥- ដូចនេះ លិខិតអនុញ្ញាតត្រូវបញ្ជាក់៖

ក- ការិយាល័យគយដើមទី ដែលត្រូវទទួលខុសត្រូវចំពោះប្រតិបត្តិការឆ្លងកាត់

ខ- នីតិវិធីនិងពេលវេលាដែលបុគ្គលជានាឆ្លងកាត់គយត្រូវជូនដំណឹងដល់ការិយាល័យគយដើមទី ដើម្បីអាចអនុវត្តការត្រួតពិនិត្យចាំបាច់នានា មុនទំនិញដឹកជញ្ជូនចេញ

គ- វិធានការដែលត្រូវអនុវត្តដើម្បីជានាថាទំនិញអាចកំណត់អត្តសញ្ញាណ រួមទាំងការប្រើប្រាស់ការកិបត្រាគយឬសៀលគយពិសេស ដោយបុគ្គលជានាឆ្លងកាត់គយ។